# Noble Park English Language School

21-35 Thomas Street, Noble Park, 3174.
Telephone: 9546 9578

P.O. Box 656, Noble Park, 3174
Fax: 9558 5683

email: noble.park.els@edumail.vic.gov.au


## Noble Park English Language School
## សេចក្តីថ្លែងនៃការប្តេជ្ញាចំពោះទំនាក់ទំនងប្រកបដោយការគោរព

យើងប្តេជ្ញាចំពោះការអនុវត្តវិធីសាស្ត្រសាលាទាំងមូល ដើម្បីទំនាក់ទំនងប្រកបដោយការគោរព
និងដើម្បីជួយប្រយុទ្ធប្រឆាំងនឹងអំពើ ហិង្សាក្នុងគ្រួសារនៅរដ្ឋវិចថូរៀ។

យើងយល់ដឹងថាៈ

- ផ្នត់គំនិតយេនឌ័រ និងវិសមភាពយេនឌ័រ គឺជាការរួមចំណែកមួយដែលនាំទៅរកអំពើហិង្សាក្នុងគ្រួសារ
- សាលារៀនរបស់យើងអាចបង្កើតការផ្លាស់ប្តូរដ៏យូរអង្វែងក្នុងឥរិយាបថ និងអាកប្បកិរិយារបស់មនុស្សវ័យក្មេង ហើយរួមចំណែក ក្នុងការដោះស្រាយអំពើហិង្សាក្នុងគ្រួសារ។

យើងទទួលស្គាល់ថា យើងមានសក្តានុពលដ៏អស្ចារ្យក្នុងការបង្កើតការផ្លាស់ប្តូរ។ សាលារៀនរបស់យើងគឺជាៈ

- កន្លែងសម្រាប់មនុស្សវ័យក្មេងរៀនសូត្រ
- កន្លែងធ្វើការដែលបុគ្គលិក សិស្ស និងក្រុមគ្រួសារទាំងអស់សមនឹងទទួលអារម្មណ៍ត្រូវបានគេគោរព មានសុវត្ថិភាព និងឱ្យតម្លៃ
- មជ្ឈមណ្ឌលសហគមន៍ដែលមានឱកាសដឹកនាំ ដាក់ឥទ្ធិពល និងរួមចំណែកដល់វប្បធម៌សហគមន៍ប្រកបដោយសុខភាពល្អ។

ជាផ្នែកនៃការប្តេជ្ញានេះៈ

- យើងទាំងអស់គ្នានឹងលើកកម្ពស់សមភាពយេនឌ័រយ៉ាងសកម្ម ហើយនិយាយប្រឆាំងនឹងអំពើហិង្សាប្រឆាំងនឹងភេទនៅសាលារៀន និងក្នុងសហគមន៍របស់យើង ដោយអនុលោមតាមក្រមសីលធម៌របស់យើង។
- បុគ្គលិកសាលារបស់យើង នឹងចូលរួមក្នុងការរៀនវិជ្ជាជីវៈដើម្បីកសាងសមត្ថភាពៈ
    - ·រៀបចំផែនការ និងអនុវត្តវិធីសាស្ត្រសាលាទាំងមូល ដើម្បីលើកកម្ពស់ទំនាក់ទំនងប្រកបដោយការគោរព
    - ·ផ្តល់ជូនកម្មវិធីសិក្សាទំនាក់ទំនងប្រកបដោយការគោរព
    - ·កំណត់ និងឆ្លើយតបចំពោះការសង្ស័យ ការលាតត្រដាង និងឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ ហើយផ្តល់ការគាំទ្រដល់ សមាជិកសហគមន៍ដែលរងផលប៉ះពាល់។
- សាលារៀនរបស់យើងនឹងទទួលធ្វើដំណើរការវាយតម្លៃ និងរៀបចំផែនការយ៉ាងហ្មត់ចត់ដើម្បីកំណត់នូវគម្លាត និងកម្រិតនៃវប្បធម៌ គោលនយោបាយ និងការអនុវត្តដែលមានស្រាប់ក្នុងសមភាពយេនឌ័រ។
- សាលារៀនរបស់យើងនឹងបង្កើតយន្តការសម្រាប់ការផ្តល់មតិឆ្លើយតបរបស់បុគ្គលិក សិស្ស និងក្រុមគ្រួសារអំពីសមភាពយេនឌ័រនៅ កន្លែងធ្វើការ/សាលារៀន។
- សាលារៀនរបស់យើងនឹងកំណត់ ហើយប្រើប្រាស់មូលនិធិសម្រាប់ទំនាក់ទំនងប្រកបដោយការគោរព និងធនធានសមស្របដទៃ ទៀតដើម្បីអនុវត្តសកម្មភាពសំខាន់ៗ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងភេទ។
- សាលារៀនរបស់យើងប្តេជ្ញាចំពោះការកែលម្អ និងការវាយតម្លៃជាបន្តលើទំនាក់ទំនងប្រកបដោយការ។

យើងទន្ទឹងរង់ចាំអបអរសាទរជោគជ័យរបស់យើង ជាមួយសហគមន៍សាលារបស់យើង ហើយរីករាយជាមួយវប្បធម៌នៃសមភាពយេនឌ័រ និងទំនាក់ទំនងប្រកបដោយការគោរពកាន់តែប្រសើរ។

| នាយកសាលា | ក្រុមប្រឹក្សាសាលា/ប្រធានក្រុមប្រឹក្សា | ប្រធានក្រុមប្រឹក្សាតំណាងសិស្ស |
| --- | --- | --- |
| V. Calabro ........................ | ........................ | ........................ |
| 22/3/22 | 28/3/2022 | 24/3/22 |